## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**
**តុលាការរដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨៦ ចុះថ្ងៃទី៣០/០៤/២០២០

សញ្ញាណរឿងក្តី៖ ប្តឹងសុំលែងលះ

សាលក្រមលេខ៖ ..៤១..../..០៥.. "ឈ"

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១

## សាលក្រម
### ក្នុងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តព្រះសីហនុ

### ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តព្រះសីហនុ

**ដើមចោទឈ្មោះ** [redacted] សោភា ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨២ ជនជាតិខ្មែរ អាសយដ្ឋាន៖ [redacted]។

**ចុងចម្លើយឈ្មោះ** [redacted] វុទ្ធា ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ អាសយដ្ឋាន៖ [redacted]។

**មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ៖** លោក [redacted] និងលោក [redacted]។

### អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.លែងលះដើមចោទឈ្មោះ [redacted] សោភា ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨២ និងចុងចម្លើយឈ្មោះ [redacted] វុទ្ធា ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៣។

២.ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510 ឱ្យដើមចោទ។

៣.ប្រគល់ផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មកឱ្យដើមចោទដើម្បីលក់ ដោយមានការ

Scanned with CamScanner

ចូលរួមព្រមព្រៀងពីចុងចម្លើយ ហើយដើមចោទត្រូវប្រគល់ប្រាក់ចំនួន ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក មកឱ្យចុងចម្លើយ ប្រាក់ដែលនៅសល់ពីនេះត្រូវប្រគល់ឱ្យដើមចោទ។ ករណីដើមចោទមានប្រាក់សុទ្ធចំនួន ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក ប្រគល់ទៅឱ្យចុងចម្លើយ ផ្ទះ និងដី មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ខាងលើត្រូវក្លាយជាកម្មសិទ្ធិរបស់ដើមចោទ។

៤.កំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនចំនួន ២នាក់ កូនទី១ឈ្មោះ [redacted] គីមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងកូនទី២ឈ្មោះ [redacted] គីមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។

៥.ប្រគល់ប្រាក់ចំនួន ២៨០០០ ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយ។

## ខ. ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១ ការសង្ខេបអំពីរឿងក្តី

ក្នុងរឿងក្តីនេះ ដើមចោទឈ្មោះ [redacted] សោភា បានដាក់ពាក្យបណ្តឹងទាមទារលែងលះចុងចម្លើយឈ្មោះ [redacted] វុទ្ធា និងស្នើសុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ ឈ្មោះ [redacted] គីមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងកូនទី២ឈ្មោះ [redacted] គីមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ព្រមទាំងស្នើសុំបែងចែកទ្រព្យសម្បត្តិរួម។

### ខ.២. អង្គហេតុដែលគ្មានវិវាទ

ខ.២.១ ដើមចោទ និង ចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ (សំបុត្រអាពាហ៍ពិពាហ៍លេខ ១១៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០) និងឯកភាពលែងលះគ្នា ដោយដើមចោទ អះអាងថា ចុងចម្លើយធ្លាប់ប្រើហិង្សាលើខ្លួន និងលួចមានស្រីខាងក្រៅ រីឯចុងចម្លើយអះអាងថា ខ្លួនមិនបានប្រើហិង្សាលើដើមចោទទេ គ្រាន់តែប្រកាយប្រតប់គ្នាបន្តិចបន្តួច ហើយដើមចោទជាអ្នកលួចមានទំនាក់ទំនងប្រុសខាងក្រៅ។

ខ.២.២ ដើមចោទ និងចុងចម្លើយមានកូនចំនួន២នាក់៖ កូនទី១ឈ្មោះ [redacted] គីមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ (សំបុត្រកំណើតលេខ ១១៥ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១) និងកូនទី២ ឈ្មោះ [redacted] គីមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ (សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧)។ ដើមចោទ និងចុងចម្លើយ ព្រមព្រៀងគ្នាប្រគល់សិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ ទៅឱ្យដើមចោទ។

ខ.២.៣ ដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួម៖ ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510, ប្រាក់ចំនួន ២៨០០០ ដុល្លារអាមេរិក និងផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ប័ណ្ណ



Scanned with CamScanner

សម្គាស់យានយន្ត, និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩)។

### ខ.៣ ចំណុចវិវាទ

គ្មាន។

### ខ.៤ ការអះអាងរបស់ភាគីទាក់ទងនឹងចំណុចវិវាទ

#### ខ.៤.១ ការអះអាងរបស់ដើមចោទ

ខ្លួន និងចុងចម្លើយបានរៀបការជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ១១៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០។ ពួកខ្លួនមានកូនពីរនាក់ កូនទី១ឈ្មោះ [redacted] គីមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងកូនទី២ឈ្មោះ [redacted] គីមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។ មូលហេតុខ្លួនស្នើសុំលែងលះចុងចម្លើយ ព្រោះចុងចម្លើយធ្លាប់ប្រើហិង្សាលើខ្លួន និងលួចលាក់មានស្រីខាងក្រៅ ក្រោយមកក៏ចុះចេញពីផ្ទះ។ ទ្រព្យសម្បត្តិរួមពួកខ្លួនមានតែ ផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ, ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510 និងប្រាក់ចំនួន ២៨000 ដុល្លារអាមេរិក (ដែលប្រាក់នេះបច្ចុប្បន្ននៅចុងចម្លើយជាអ្នកគ្រប់គ្រង)។ ខ្លួន និងចុងចម្លើយបានព្រមព្រៀងដូចខាងក្រោម៖

១.លែងលះដើមចោទឈ្មោះ [redacted] សោភា ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨២ និងចុងចម្លើយឈ្មោះ [redacted]វុទ្ធា ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៣។

២.ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510 ឱ្យដើមចោទ។

៣.ប្រគល់ផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មកឱ្យដើមចោទដើម្បីលក់ ដោយមានការចូលរួមព្រមព្រៀងពីចុងចម្លើយ ហើយដើមចោទត្រូវប្រគល់ប្រាក់ចំនួន ៤០000 (បួនម៉ឺន) ដុល្លារអាមេរិក មកឱ្យចុងចម្លើយ ប្រាក់ដែលនៅសល់ពីនេះត្រូវប្រគល់ឱ្យដើមចោទ។ ករណីដើមចោទមានប្រាក់សុទ្ធចំនួន ៤០000 (បួនម៉ឺន) ដុល្លារអាមេរិក ប្រគល់ទៅឱ្យចុងចម្លើយ ផ្ទះ និងដី មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ខាងលើត្រូវក្លាយជាកម្មសិទ្ធិរបស់ដើមចោទ។

៤.កំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនចំនួន ២នាក់ កូនទី១ឈ្មោះ [redacted] គីមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងកូនទី២ឈ្មោះ [redacted] គីមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។

៥.ប្រគល់ប្រាក់ចំនួន ២៨000 ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយ។

ចំពោះបំណុលជំពាក់ធនាគារ ខ្លួនជាអ្នកធានារ៉ាប់រងសង ហើយសោហ៊ុយចិញ្ចឹមកូនបីបាច់ថែរក្សាកូន គឺខ្លួនមិនទាមទារទេ។

### ខ.៤.២ ការអះអាងរបស់ចុងចម្លើយ

ខ្លួន និងដើមចោទ ពិតជាបានរៀបការជាមួយគ្នា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ និងមានកូនចំនួនពីរនាក់ កូនទី១ឈ្មោះ [redacted] គឹមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងកូនទី២ឈ្មោះ [redacted] គឹមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។ ខ្លួនឯកភាពលែងលះជាមួយដើមចោទ ព្រោះដើមចោទមានទំនាក់ទំនងជាមួយប្រុសខាងក្រៅ។ ខ្លួនឯកភាពតាមសេចក្តីថ្លែងការណ៍របស់ភាគីដើមចោទខាងលើ ដោយមូលហេតុពួកខ្លួនបានចរចារ និងព្រមព្រៀងគ្នា ដូចការអះអាងរបស់ដើមចោទខាងលើ។

## សំអាងហេតុ

**តាមលទ្ធផលនៃការសាកសួរសាមីដើមចោទ និងចុងចម្លើយ**

**និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖**

### ក.ស្តីពីការទាមទារប្តឹងសុំលែងលះចុងចម្លើយ

១.តាមឯកសារជាភស្តុតាងមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ១១៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ របស់គូភាគីអាចបញ្ជាក់បានថា ដើមចោទ និងចុងម្លើយ ពិតជាបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលអាចឱ្យតុលាការលើកមកពិចារណាការស្នើសុំលែងលះរបស់ដើមចោទ តាមក្រមរដ្ឋប្បវេណី។

២.ដើមចោទ និងចុងចម្លើយ ព្រមព្រៀងលែងលះគ្នា ដោយបានចោទគ្នាទៅវិញទៅមកថាលួចមានទំនាក់ទំនងជាមួយបុគ្គលខាងក្រៅ ហើយតុលាការបានព្យាយាមផ្សះផ្សាឱ្យដើមចោទ និងចុងចម្លើយរួមរស់នៅជាមួយគ្នាឡើងវិញ តែគូភាគីនៅតែមិនព្រម ដែលនេះបង្ហាញឱ្យឃើញថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ និងគ្មានសង្ឃឹមថាអាចធ្វើបដិទានឡើងវិញបាន។ ហេតុដូច្នេះគប្បីតុលាការសម្រេចឱ្យភាគីលែងលះគ្នា តាមមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី។

### ខ.ស្តីពីការទាមទារសិទ្ធគ្រប់គ្រងកូន

១.តាមសំបុត្រកំណើតលេខ ១១៥ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] គឹមជូ និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] គឹមហេង អាចបញ្ជាក់បានថាឈ្មោះ [redacted] គឹមជូ និងឈ្មោះ [redacted] គឹមហេង ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយប្រាកដមែន។

២.ដើមចោទ និងចុងចម្លើយបានពិភាក្សា និងព្រមព្រៀងជាមួយគ្នាប្រគល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] គឹមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងឈ្មោះ [redacted] គឹមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ទៅឱ្យដើមចោទជាអ្នកមានអំណាចមេបា។ ហេតុដូច្នេះគប្បីតុលាការសម្រេចកំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនទាំងពីរតាមការពិភាក្សារបស់ភាគី អនុលោមតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

Scanned with CamScanner

## គ.ស្តីពីការស្នើសុំបែងចែកទ្រព្យសម្បត្តិរួម

១.តាមការអះអាងរបស់គូភាគី, វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៩ និងប័ណ្ណសម្គាល់យានយន្ត បញ្ជាក់បានថា ផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ, ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510 និងប្រាក់ចំនួន ២៨០០០ ដុល្លារអាមេរិក ពិតជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយ។

២.ដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាប្រគល់ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510 ឱ្យដើមចោទ, ប្រគល់ប្រាក់ចំនួន ២៨០០០ ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយ, និងប្រគល់ផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មកឱ្យដើមចោទដើម្បីលក់ ដោយមានការចូលរួមព្រមព្រៀងពីចុងចម្លើយ ហើយដើមចោទត្រូវប្រគល់ប្រាក់ចំនួន ៤០០០០(បួនម៉ឺន) ដុល្លារអាមេរិក មកឱ្យចុងចម្លើយ ប្រាក់ដែលនៅសល់ពីនេះត្រូវប្រគល់ឱ្យដើមចោទ។ ករណីដើមចោទមានប្រាក់សុទ្ធចំនួន ៤០០០០(បួនម៉ឺន) ដុល្លារអាមេរិក ប្រគល់ទៅឱ្យចុងចម្លើយ ផ្ទះ និងដី មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ខាងលើ ត្រូវក្លាយជាកម្មសិទ្ធិរបស់ដើមចោទ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការពិភាក្សារបស់ភាគី អនុលោមតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី។

## ឃ.ស្តីពីបន្ទុកប្រាក់ប្រដាប់ក្តី

ជាគោលការណ៍ ប្រាក់ប្រដាប់ក្តីជាបន្ទុកភាគីចាញ់ក្តី ប៉ុន្តែក្នុងរឿងក្តីនេះ ភាគីបានព្រមព្រៀងគ្នាក្នុងការលែងលះ។ ហេតុដូច្នេះគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយទទួលនូវបន្ទុកប្រាក់ប្រដាប់ក្តីម្នាក់ពាក់កណ្តាល (មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា)។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-លែងលះដើមចោទឈ្មោះ [redacted] សោភា ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨២ និងចុងចម្លើយឈ្មោះ [redacted] វុទ្ធា ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៣។

២-ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាក SUZUKI LATE មានផ្លាកលេខ ព្រះសីហនុ 1D-7510 ឱ្យដើមចោទ។

៣-ប្រគល់ផ្ទះ និងដី ០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានទំហំ ៤.៦៥ ម៉ែត្រ គុណនឹង ៣០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មកឱ្យដើមចោទដើម្បីលក់ ដោយមានការចូលរួមព្រមព្រៀងពីចុងចម្លើយ ហើយដើមចោទត្រូវប្រគល់ប្រាក់ចំនួន ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក មកឱ្យចុងចម្លើយ ប្រាក់ដែល



Scanned with CamScanner

នៅសល់ពីនេះត្រូវប្រគល់ឱ្យដើមចោទ។ ករណីដើមចោទមានប្រាក់សុទ្ធចំនួន ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក ប្រគល់ទៅឱ្យចុងចម្លើយ ផ្ទះ និងដី មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៥១៩ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ខាងលើ ត្រូវក្លាយជាកម្មសិទ្ធិរបស់ដើមចោទ។

៤-កំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនចំនួន ២នាក់ កូនទី១ឈ្មោះ [redacted] គីមជូ ភេទស្រី ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ និងកូនទី២ឈ្មោះ [redacted] គីមហេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៦។

៥-ប្រគល់ប្រាក់ចំនួន ២៨០០០ ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយម្នាក់ពាក់កណ្តាល។

សាលក្រមនេះត្រូវបានប្រកាសនៅសវនការជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងចុងចម្លើយ។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ព្រះសីហនុ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner